ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:...០០១/២០.....គ.ម.ក./ប្រក.

# ប្រកាស

## ស្ដីពី

## ភាតព្វកិច្ចផ្ដល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាត របស់ក្រុមហ៊ុនសមាគីកណ្ដាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ

អាសយដ្ឋាន: អគារ 168F ផ្លូវ 598 សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ-កម្ពុជា
Address: Building 168F, Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ
- បានឃើញប្រកាសលេខ ០០៨/១៩ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មឧបករណ៍និស្សន្ទ
- បានឃើញប្រកាសលេខ ០០៥/២០ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ស្តីពីវិសោធនកម្មលើប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់ពីកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងបទប្បញ្ញត្តិដទៃទៀតក្នុងវិស័យមូលបត្រ ដើម្បីត្រួតពិនិត្យ និងតាមដានទូវការបំពេញកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

### ប្រការ ៣.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងមាននៅក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ និងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មឧបករណ៍និស្សន្ទ។

**ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត**÷ សំដៅដល់ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

**បុគ្គលិកជាន់ខ្ពស់÷** សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុនដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងអភិបាល។

**បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ÷** សំដៅដល់អភិបាល ឬសហកម្មសិទ្ធករ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ ប្រធានផ្នែកគ្រប់គ្រងហានិភ័យ ប្រធានផ្នែកព័ត៌មានវិទ្យា បុគ្គលិកជំនាញផ្នែកច្បាប់ និងប្រធានផ្នែកផ្សេងទៀតដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.**។

**អនុក្រឹត្យ÷** សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

## ជំពូកទី ២
## ភារកិច្ចផ្ដល់របាយការណ៍

### ប្រការ ៤.- របាយការណ៍ប្រចាំសប្ដាហ៍

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្ដល់ជូន **គ.ម.ក.** ជាប្រចាំសប្ដាហ៍ នូវរបាយការណ៍ស្ដីពីការជួញដូរឧបករណ៍និស្សន្ទ តាមរយៈអ៊ីមែល ឬមធ្យោបាយផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ៥.- របាយការណ៍ប្រចាំខែ

ក្រុមហ៊ុនសមភាគីកណ្ដាលត្រូវផ្ដល់ជូន **គ.ម.ក.** ជាប្រចាំខែ នូវរបាយការណ៍ស្ដីពីការជួញដូរឧបករណ៍និស្សន្ទ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវផ្ដល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំខែដូចខាងក្រោម÷

១-របាយការណ៍ស្ដីពីការជួញដូរឧបករណ៍និស្សន្ទ។

២-របាយការណ៍សរុបស្ដីពីការដាក់-ដកសាច់ប្រាក់របស់អតិថិជន។

៣-របាយការណ៍ធនាគារនៃគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទ។

៤-របាយការណ៍ស្ដីពីការបើក-បិទគណនីជួញដូររបស់អតិថិជននីមួយៗ។

៥-របាយការណ៍ស្ដីពីចំនួនអតិថិជនសរុប។

### ប្រការ ៦.- របាយការណ៍ប្រចាំឆមាស

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្ដល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំឆមាសដូចខាងក្រោម÷

១-របាយការណ៍ហិរញ្ញវត្ថុផ្ទៃក្នុងដែលបានរៀបចំអនុលោមតាមច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម។

២-របាយការណ៍ស្ដីពីការត្រួតពិនិត្យផ្ទៃក្នុង។

៣-របាយការណ៍អំពីនិយោជិត បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ និងភ្នាក់ងារនៃក្រុមហ៊ុនសមភាគីកណ្ដាល ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ។

៤-របាយការណ៍ស្ដីពីការវាយតម្លៃរបស់បុគ្គលិកជំនាញផ្នែកច្បាប់លើអនុលោមភាពតាមច្បាប់របស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត។

៥-របាយការណ៍ស្តីពីការដោះស្រាយវិវាទ និងពាក្យបណ្តឹង។

**ប្រការ ៧.- របាយការណ៍ប្រចាំឆ្នាំ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម÷

១-របាយការណ៍អំពីសមិទ្ធផល និងបញ្ហាប្រឈម ដែលអនុវត្តតាមផែនការអាជីវកម្មដែលបានដាក់តម្កល់នៅ **គ.ម.ក.**។

២-អង្គការលេខបច្ចុប្បន្ន។

៣-រចនាសម្ព័ន្ធបច្ចុប្បន្នដោយបញ្ចូលទាំងក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ សាខា និងការិយាល័យតំណាងទាំងអស់របស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត។

៤-របាយការណ៍សវនកម្ម និងលិខិតផ្សេងៗដែលទទួលបានពីសវនករឯករាជ្យ ប្រសិនមាន។

៥-លិខិតបញ្ជាក់ពីក្រុមហ៊ុនពាក់ព័ន្ធដែលជានាកាតព្វកិច្ចបំណុលនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបុត្រសម្ព័ន្ធទាំងអស់របស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងឯកសារពាក់ព័ន្ធ ប្រសិនមាន។

៦-កិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ប្រសិនមាន។

៧-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៨.- កាលបរិច្ឆេទនៃការផ្តល់របាយការណ៍**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់របាយការណ៍ជូន **គ.ម.ក.** តាមកាលបរិច្ឆេទដូចខាងក្រោម ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**÷

១-របាយការណ៍ប្រចាំសប្តាហ៍យ៉ាងយូរត្រឹមថ្ងៃចន្ទនៃសប្តាហ៍បន្ទាប់។

២-របាយការណ៍ប្រចាំខែយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់។

៣-របាយការណ៍ប្រចាំឆមាសក្នុងរយៈពេលយ៉ាងយូរ ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃបញ្ចប់ឆមាស។

៤-របាយការណ៍ប្រចាំឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនានៃឆ្នាំបន្ទាប់។

ក្នុងករណីដែលកាលបរិច្ឆេទចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះត្រូវចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកសាធារណៈ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់របាយការណ៍នៅថ្ងៃធ្វើការបន្ទាប់។

## ជំពូកទី ៣
## កាតព្វកិច្ចជូនដំណឹង

**ប្រការ ៩.- ការប្រែប្រួលស្ថានភាពគ្រប់គ្រង និងហិរញ្ញវត្ថុ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **គ.ម.ក.** អំពីការប្រែប្រួលនៃស្ថានភាពណាមួយដូចខាងក្រោមដែលអាចជះឥទ្ធិពលដល់ក្រុមហ៊ុនក្នុងការប្រកបអាជីវកម្ម

ឧបករណ៍និស្សន្ទ ឬដល់អតិថិជនរបស់ក្រុមហ៊ុន÷

១- ស្ថានភាពគ្រប់គ្រងរបស់ក្រុមហ៊ុន។

២- ទ្រព្យសកម្មរបស់ក្រុមហ៊ុន។

៣- ស្ថានភាពឥណទាន ឬបំណុលរបស់ក្រុមហ៊ុន។

៤- ស្ថានភាពវិនិយោគរបស់ក្រុមហ៊ុន។

៥- រចនាសម្ព័ន្ធប្រាក់ចំណេញរបស់ក្រុមហ៊ុន។

៦- ការប្រែប្រួលផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ថានភាពគ្រប់គ្រង និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការជូនដំណឹងត្រូវរួមបញ្ចូលទាំងការវាយតម្លៃអំពីឥទ្ធិពលនៃការប្រែប្រួលទាំងនោះលើក្រុមហ៊ុន និងអតិថិជនរបស់ក្រុមហ៊ុន ព្រមទាំងសកម្មភាព ឬវិធានការទាំងអស់ដែលក្រុមហ៊ុនធ្វើឡើងដើម្បីគ្រប់គ្រងការប្រែប្រួលនោះ។

## ប្រការ ១០.- ការទាមទារសំណង និងការផ្លាស់ប្តូរកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ

ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើការទាមទារសំណងក្នុងក្របខ័ណ្ឌកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ឬធ្វើការផ្លាស់ប្តូរដែនកំណត់នៃកិច្ចសន្យានោះ ដែលទាក់ទងនឹងអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីមានការទាមទារសំណង ឬការផ្លាស់ប្តូរកិច្ចសន្យានោះ។

## ប្រការ ១១.- ការជូនដំណឹងអំពីការប្រព្រឹត្តល្មើសឬហេតុការណ៍ដែលស្ថិតក្នុងស្ថានភាពពិសេសណាមួយ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់មក **គ.ម.ក.** ប្រសិនបើក្រុមហ៊ុននោះ ក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ សាខា ការិយាល័យតំណាង ភាគហ៊ុនិក សហកម្មសិទ្ធិករ ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននោះ ដែលកំពុងបំពេញ ឬបានបញ្ចប់មុខងារ ដែលក្នុងអំឡុងពេលបំពេញមុខងារដោយបុគ្គលទាំងនោះ បាន÷

១- រងការស៊ើបអង្កេត រងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានពិរុទ្ធភាព ឬត្រូវបានផ្តន្ទាទោសដោយសារការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅក្នុងយុត្តាធិការណាមួយ។

២- ជាប់បណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ច ឬការអនុវត្តវិជ្ជាជីវៈក្នុងវិស័យមូលបត្រនៅក្នុងយុត្តាធិការណាមួយ។

៣- ទទួលរងពិន័យអន្តរការណ៍ ព្យួរ ឬដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត ឬត្រូវបានបដិសេធមិនឱ្យចុះបញ្ជី/អាជ្ញាបណ្ណ/ការអនុញ្ញាត ដោយនិយ័តករ ស្ថាប័នស្វ័យនិយ័តករ ឬអង្គភាពវិជ្ជាជីវៈក្នុងយុត្តាធិការណាមួយ។

## ប្រការ ១២.- ការផ្លាស់ប្តូរ ឬមូលហេតុដែលប៉ះពាល់អាជ្ញាបណ្ណ/ការអនុញ្ញាត

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលមានហេតុការណ៍ ឬមូលហេតុណាមួយដែល

បណ្តាលឱ្យក្រុមហ៊ុនអាចឈានទៅរកការជម្រះបញ្ជី ការរំលាយក្រុមហ៊ុន ការផ្អាក ឬការឈប់ធ្វើអាជីវកម្មឧបករណ៍និស្សន្ទ។

### ប្រការ ១៣.- បុត្រសម្ព័ន្ធ និងក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់មក **គ.ម.ក.** ក្នុងករណីមានចំណុចណាមួយដូចខាងក្រោម កើតឡើងចំពោះបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង/ក្រុមហ៊ុនមេនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា÷

១-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការធ្វើអនុប្បទានអាជីវកម្មដោយផ្នែក ឬទាំងស្រុង។

២-ការហាមឃាត់ ឬការដាក់កម្រិតក្នុងការចេញមូលបត្រទានប័ត្រ។

៣-ការចេញសេចក្តីសម្រេចរំលាយក្រុមហ៊ុន។

៤-ការចាប់ផ្តើមនៃនីតិវិធីណាមួយទាក់ទងនឹងនីតិវិធីនៃការក្ស័យធន។

៥-ករណីផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៤
## ភាតព្វកិច្ចស្នើសុំការអនុញ្ញាត

### ប្រការ ១៤.- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញក្រុមហ៊ុន និងការផ្ទេរប្រតិបត្តិការអាជីវកម្ម

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងរំលាយក្រុមហ៊ុនបញ្ចូលគ្នា ទិញក្រុមហ៊ុន ឬផ្ទេរប្រតិបត្តិការអាជីវកម្ម។

### ប្រការ ១៥.- ការជម្រះបញ្ជី ការរំលាយ ការផ្អាក និងការឈប់ធ្វើអាជីវកម្មឧបករណ៍និស្សន្ទ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុនចាប់ផ្តើមការជម្រះបញ្ជី ការរំលាយ ការផ្អាក ឬការឈប់ធ្វើអាជីវកម្មឧបករណ៍និស្សន្ទ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់ជូន **គ.ម.ក.** នូវនីតិវិធី និងឯកសារពាក់ព័ន្ធនឹងការឈប់ធ្វើអាជីវកម្មឧបករណ៍និស្សន្ទក្នុងរយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ មុនថ្ងៃឈប់ធ្វើអាជីវកម្ម។ នីតិវិធី និងរយៈពេលនៃការអនុវត្តនីតិវិធីឈប់ធ្វើអាជីវកម្មត្រូវទទួលការយល់ព្រមពីអគ្គនាយកនៃ **គ.ម.ក.**។ ក្នុងករណីការអនុវត្តនីតិវិធីនៃការឈប់ធ្វើអាជីវកម្ម ប្រើប្រាស់ពេលលើសពីរយៈពេលទទួលបានការអនុញ្ញាត អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិកំណត់រយៈពេលបន្ថែម។

ការឈប់ធ្វើអាជីវកម្មឧបករណ៍និស្សន្ទត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យស្តីពីបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ ក្នុងករណីជម្រះបញ្ជីដោយស្ម័គ្រចិត្ត។

### ប្រការ ១៦.- ការបង្កើតបុត្រសម្ព័ន្ធ និងការិយាល័យតំណាង

មុនពេលបង្កើតបុត្រសម្ព័ន្ធ បើក ឬបិទការិយាល័យតំណាង ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបំពេញលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក.**។

រាល់របាយការណ៍ដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់ជូន **គ.ម.ក.** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ត្រូវរួមបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងបុគ្គលសម្ព័ន្ធ និងការិយាល័យតំណាងនៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៥
## បទប្បញ្ញត្តិផ្សេងៗ

### ប្រការ ១៧.- ការយកចិត្តទុកដាក់ក្នុងការរៀបចំរបាយការណ៍

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវរៀបចំរាល់របាយការណ៍ និងព័ត៌មានអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់ដើម្បីធានាឱ្យបាននូវភាពសុក្រឹត ច្បាស់លាស់ និងពេញលេញ។ ប្រសិនបើមានកំហុសឆ្គង ឬការខ្វះខាតណាមួយត្រូវបានរកឃើញ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **គ.ម.ក.** និងត្រូវផ្តល់សារជាថ្មីនូវរបាយការណ៍ និងព័ត៌មានដែលកែតម្រូវរួច។

### ប្រការ ១៨.- ភារកិច្ចផ្តល់ព័ត៌មាន និងឯកសារតាមការស្នើសុំ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.** ដើម្បីកំណត់ពីភាពត្រឹមត្រូវនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតក្នុងការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ ឬសេចក្តីណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ១៩.- ទម្រង់នៃរបាយការណ៍ និងការផ្តល់ព័ត៌មាន

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវរៀបចំរបាយការណ៍ និងផ្តល់ព័ត៌មានអនុលោមតាមប្រកាសនេះ ក្នុងទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

### ប្រការ ២០.- ពិន័យអន្តរការណ៍

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលប្រព្រឹត្តល្មើស ឬផ្តល់ព័ត៌មានខុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរនឹងប្រការ ៤, ប្រការ ៥, ប្រការ ៦, ប្រការ ៧, ប្រការ ៩, ប្រការ ១០, ប្រការ ១១, ប្រការ ១២, ប្រការ ១៣, ប្រការ ១៤, ប្រការ ១៥, ប្រការ ១៦, ប្រការ ១៧, ប្រការ ១៨, ប្រការ ១៩ ឬមិនគោរពតាមសេចក្តីណែនាំ ការកំណត់ ឬការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.** ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងនៅក្នុងប្រការ ២១ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់មិនលើសពី

២០០.០០០.០០០ (ពីររយលាន) រៀល។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ ឬការជូនដំណឹងតាមរយៈពេល ឬកាលបរិច្ឆេទដូចមានកំណត់នៅក្នុងប្រការ ៨ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ២១ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ដូចខាងក្រោម÷

១- ចំនួន ១.០០០.០០០ (មួយលាន) រៀលក្នុងមួយថ្ងៃ ចំពោះការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំជូន **គ.ម.ក.**។

២- ចំនួន ៤០០.០០០ (បួនរយពាន់) រៀល ក្នុងមួយថ្ងៃ ចំពោះការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ប្រចាំសប្តាហ៍។

ក្នុងករណីមិនរាងចាល បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលពិន័យអន្តរការណ៍ទ្វេរដង។

ក្នុងករណីការប្រព្រឹត្តល្មើសបានបង្កឱ្យមានព្យសនកម្ម បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលរងពិន័យអន្តរការណ៍ពី **គ.ម.ក.** និង/ឬជួសជុលសំណងព្យសនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មុននឹងចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី ១, កថាខណ្ឌទី ២, កថាខណ្ឌទី ៣ ឬកថាខណ្ឌទី ៤ នៃប្រការនេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

### ប្រការ ២១.- ទណ្ឌកម្មរដ្ឋបាល

ទណ្ឌកម្មរដ្ឋបាលមានដូចខាងក្រោម÷

១- ការព្រមាន ឬដាស់តឿន។

២- ការដឹកនាំកែតម្រង់។

៣- ការព្យួរ ឬបណ្តេញបុគ្គលិកជាន់ខ្ពស់ចេញពីមុខតំណែង។

៤- ការដាក់កំហិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត។

៥- ការព្យួរអាជ្ញាបណ្ណ/ការអនុញ្ញាត។

៦- ការដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

### ប្រការ ២២.- គោលការណ៍ណែនាំ

អគ្គនាយកនៃ **គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងប្រកាសនេះដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

### ប្រការ ២៣.- បដិវិធានកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ២៤.- ការអនុវត្ត**

អគ្គនាយកនៃ **គ.ម.ក.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋាន-អង្គភាពស្ថិតនៅចំណុះឱ្យ **គ.ម.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៤
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ